# រឿងព្រះសុធននាងកែវមនោហ័រាក្នុងរបាំក្បាច់បុរាណខ្មែរ

ឯកសារ ជាពិសេសសិលាចារឹកនិងចម្លាក់លើជញ្ជាំងប្រាសាទបុរាណខ្មែរ បានបញ្ជាក់ច្បាស់ជាតឹកតាងថារបាំព្រះរាជទ្រព្យឬរបាំក្បាច់បុរាណខ្មែរ មានវត្តមាន តាំងតែពីសម័យបុរេអង្គរមកម្ល៉េះ។ នាសម័យអង្គរដ៏រុងរឿង (សតវត្សទី៩-១៥) វប្បធម៌អរិយធម៌ខ្មែរលូតលាស់ដល់កំពូល។ បុព្វបុរសខ្មែរបានបន្សល់ទុកដល់សព្វថ្ងៃ នូវស្នាដៃសិលាប្រាសាទបុរាណដែលជាមរតកដ៏មានតម្លៃកាត់ថ្លៃមិនបាន ជាកេរតំណែលដូនតា អត្តសញ្ញាណជាតិ និងជាដួងព្រលឹងរបស់ខ្មែរ។

របាំដ៏សុក្រឹតល្អឥតខ្ចោះប្រកបដោយក្បួនខ្នាតត្រឹត្យក្រមកំពូល មានរបាំអប្សរា ជាដើម ជាស្នាដៃសិល្បៈមានជីវិតរស់រវើកនៅលើឆាកទស្សនីយភាពល្បីល្បាញទូទាំងប្រទេសនិងពិភពលោក។ នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០៣ របាំព្រះរាជទ្រព្យខ្មែរ ត្រូវបានអង្គការយូណេស្កូទទួលស្គាល់ជាសម្បត្តិបេតិកភណ្ឌពិភពលោក និងបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ។ របាំនិងល្ខោនព្រះរាជទ្រព្យឬក្បាច់បុរាណ ខ្មែរ យករឿងព្រេងជាតកវីរកថា និងទេវកថា មកអភិវឌ្ឍជាទស្សនីយភាព ដូចជារឿងព្រះជិនវង្ស ព្រះចន្ទគោរព ព្រះវេស្សន្តរ រាមកេរ្តិ៍ និងព្រះសុធន នាងកែវមនោហ័រា ជាដើម។ល។

រឿងព្រះសុធននាងកែវមនោហ័រាមានដំណើររឿងដូចខាងក្រោមនេះ៖ ថ្ងៃព្រៃបុណ្ឌរិកបាននាំព្រះសុធនទៅចាំលបមើលនាងទេពកញ្ញា៧ព្រះអង្គ ដែលកំពុងសប្បាយលេងក្នុងស្រះបោក្ខរណី។ ឆ្លៀតឱកាសនោះ ព្រះសុធនលបលួចយកស្បៃនាងកែវមនោហ័រាទៅលាក់ទុក។ រំពេចនោះ សូរស័ព្ទសម្លេងឃ្មោះលាន់រំពងឡើង ដែលជាសញ្ញាសន្មតដល់ពេលវេលាដែលនាងទេពអប្សរត្រូវត្រឡប់ទៅស្ថានកៃលាសវិញ។ នាងទេពអប្សរទាំង៧ក៏ម៉ីម្នាឡើងពីស្រះរៀបចំខ្លួនពាក់ស្បៃដើម្បីហោះត្រឡប់ ទៅស្ថានកៃលាសវិញ។ ដោយឡែក នាងពៅកែវមនោហ័រាយំសោករហូតដល់សន្ធប់ ព្រោះនាងរកស្បៃពុំឃើញ ហើយត្រូវបងៗហោះទៅចោលបាត់អស់។ បានឱកាសល្អ ព្រះសុធន ចេញមកជួយយកអាសារហើយលួងលោមប្រលោមស្នេហ៍ រួចនាំនាង កែវមនោហ័រា មករួមរស់ក្នុងព្រះរាជវាំងតរៀងទៅ។

អត្ថបទដោយ៖

## អត្ថបទ៖ រឿងព្រះសុធននាងកែវមនោហ៍រាក្នុងរបាំក្បាច់បុរាណខ្មែរ

ថ្ងៃមួយ នគរឧត្តរបញ្ចាល កើតមានកលយុគដោយមានសត្រូវចូលឈ្លានពាន។ ព្រះបាទ វង្សាអនិច្ចៈ ជាបិតាបានត្រាស់បញ្ជាឱ្យ ព្រះសុធន ជាបុត្រារៀបចំពលសេនាយោធា ចេញច្បាំងកំចាត់សត្រូវ យកអាសារព្រះនគរឱ្យរួចផុតពីគ្រោះភ័យ។

ថ្ងៃងពីព្រះមាតានៃព្រះសុធន ព្រះនាងចន្ទាទេវី ទ្រង់យល់សុបិននិម្មិត ឃើញហេតុគួររន្ធត់។ ហេតុតែកម្មវេរាពីជាតិមុនបណ្ដាលឱ្យព្រាហ្មណ៍មានចិត្តប្រទូស្ត និយាយបំផ្លើសបង្វែរ សុបិនដែលល្អឱ្យទៅជាអាក្រក់ដោយពោលថា បើមិនប្រហារនាង កែវមនោហ៍នោះទេ ព្រះនគរនឹងកើតគ្រោះភ័យចង្រៃ ហើយព្រះសុធននឹងត្រូវក្ស័យ ព្រះជន្មាទៀតផង។ ព្រះបិតាព្រះមាតានៃព្រះសុធន ដោយមានចិត្តសន្ដោសប្រណី មិនបានប្រល័យនាងកែវមនោហ៍រាទេ គ្រាន់តែបំបោះបង់ព្រះនាងឱ្យចាកចេញពី ព្រះនគរប៉ុណ្ណោះ។ ពេលធ្វើដំណើរតាមផ្លូវ ព្រះនាងបានជួបនឹងមហាឥសីមួយអង្គ ហើយបានដោះព្រះទម្រង់ផ្ញើរទុកថ្វាយព្រះសុធន ក្រែងទ្រង់យាងតាមរកព្រះនាង។

ក្រោយពីព្រះសុធន ធ្វើសង្គ្រាមមានជោគជ័យ ព្រះអង្គក៏យាងចូលព្រះនគរវិញដោយទទួលអំណរសាទរពីនាម៉ឺនសព្វមុខមន្ត្រីនិងអាណាប្រជានុរាស្ត្រគ្រប់គ្នា។ លុះទ្រង់ជ្រាបហេតុការណ៍អំពីរឿងបាត់ព្រះមហេសី ព្រះអង្គស្ដុតស្មារតីយ៉ាងខ្លាំង ទើបទ្រង់សូមអនុញ្ញាតពីព្រះបិតាមាតាទៅតាមរកនាងកែវមនោហ៍រានៅឯស្ថានកៃលាស។

នៅពាក់កណ្ដាលផ្លូវ ព្រះសុធនបានជួបនឹងមហាឥសី ហើយក៏បានទទួលព្រះទម្រង់ដែលជាបញ្ញើរបស់នាងកែវមនោហ៍រា។ ទ្រង់បន្តដំណើរយ៉ាងវែងឆ្ងាយ ដោយជួបប្រទះនូវឧបសគ្គជាច្រើន រហូតបានទៅដល់ស្ថានកៃលាសដូចព្រះរាជ ហឫទ័យ។

ព្រះសុធន ទ្រង់គង់ក្នុងសាលាសំណាក់ក្បែរស្រះស្រង់មួយអស់ជាច្រើនថ្ងៃ ហើយបានទតឃើញស្រីស្នំជាច្រើនមកដងទឹកក្នុងស្រះនោះ។ ទ្រង់ក៏បានសូត្រអាគមគាថាធ្វើឱ្យក្អមទឹករបស់ស្នំម្នាក់មានទម្ងន់ធ្ងន់លើកមិនរួច។ លុះស្រីស្នំឯទៀតទៅចោល អស់នៅតែស្នំម្នាក់ដែលលើកក្អមមិនរួច ទើបព្រះសុធនយាងចេញមកសាកជួយលើកក្អម ហើយក៏បានលួចដាក់ព្រះទម្រង់នៅក្នុងក្អមទឹកនោះផង។

ដោយព្រេងនិស្ស័យជាគូពីបុព្វេ នៅពេលដែលស្នំចាក់ទឹកក្អមស្រោចសុគន្ធវារី ថ្វាយព្រះនាងកែវមនោហ៍រា យកព្រះហស្តជ្រោងព្រះកេសា។ គ្រានោះ ព្រះទម្រង់ក៏ធ្លាក់ជាប់

អត្ថបទដោយ៖

ម្រាមព្រះហស្តក្សត្រិយ។ ក្រោយពីព្រះនាងទ្រង់ជ្រាបសេចក្តី ពីស្រីស្នំហើយ ព្រះនាងកែវមនោហ៍រា មិនបង្អង់យូរឡើយ ស្តេចក៏យាងទៅរកព្រះសុធន នៅឯមាត់ស្រះ។

នៅពេលដែលក្សត្រទាំងពីរព្រះអង្គកំពុងសារសង់ដោយក្តីនឹករឭក ព្រះបាទទុម្ពរ និងព្រះអគ្គមហេសី ដែលជាព្រះបិតាព្រះមាតានៃព្រះនាងកែវមនោហ៍រា ទ្រង់ក៏បានស្តេចយាងមកដល់ស្រះ ហើយបានទតឃើញនិងដឹងនូវហេតុទាំងអស់រវាងបុត្រី និងព្រះសុធន។ ដោយទ្រង់យល់រូបឆោមនៃព្រះសុធនធិបតី មានឫទ្ធិចេស្តារុងរឿង សក្តិសមនឹងរាជបុត្រី ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យព្រមទទួលអភិសេកព្រះសុធន ជារាជសុណិសារឱ្យនៅជាសុខតរៀងទៅហោង៕

## ឯកសារពិគ្រោះ


ពេជ្រ ទុំក្រវិល. (២០០៣). *សិល្បៈទស្សនីយភាពខ្មែរ*. ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

________. (២០០១). *របាំខ្មែរ*. ភ្នំពេញ: អង្គការមូលនិធិតូយ៉ូតា។

Cravath, Paul. (2007). *Earth in Flower*. Holmes Beach, FL: DatASIA.

Sam, Chan Moly. (1987). *Khmer Court Dance*. Newington, CT: Khmer Studies Institute.


អរិយធម៌ខ្មែរ
KHMER CIVILIZATION